២-អនុគណនី	៧៣០៨៧	ចំណូលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន	ចំនួនទឹកប្រាក់	176,600,000	រៀល
៣-អនុគណនី	៧៤០១២	ចំណូលពីការផាកពិន័យ និងទោសទណ្ឌ	ចំនួនទឹកប្រាក់	110,000,000	រៀល
			សរុបទឹកប្រាក់	3,663,600,000	រៀល

ប្រការ២.-

ចំនួនទឹកប្រាក់អតិបរមា ដែលអនុញ្ញាតទុកនៅក្នុងបេឡាមានកំណត់ត្រឹមចំនួន 2,000,000 រៀល (ពីរលានរៀលគត់)

ប្រការ៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៤.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ អគ្គាធិការ និង

អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុរបស់ក្រសួងទេសចរណ៍ ប្រធានគ្រប់អង្គភាពក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៨កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៩

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រី
ក្រសួងទេសចរណ៍

ថោង ខុន

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible] សហវ.ប្រក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាសអន្តរក្រសួង

ស្តីពី

កិច្ចសហការរវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានកម្ពុជា
ត្រួតពិនិត្យទំនិញនីហរណ៍ អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

រដ្ឋមន្ត្រី
ក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ឱ្យទៅជាអគ្គនាយដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ចំណុះក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា ២ មាត្រា ៣ មាត្រា ៤ និងបន្ថែមមាត្រា ៨ស្ទួន នៃអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ឱ្យទៅជាអគ្គនាយដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ចំណុះក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលស្ថាប័នមានសមត្ថកិច្ចត្រួតពិនិត្យទំនិញនាំចេញ-នាំចូលដើម្បីសម្រួលពាណិជ្ជកម្ម និងពង្រឹងភាពប្រកួតប្រជែងកម្ពុជា
- បានឃើញប្រកាសអន្តរក្រសួងលេខ ៩៩៤ សហវ.ប្រក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- យោងតាមសំណូមពរការងារចាំបាច់

សម្រេច

ប្រការ ១.-

ប្រកាសអន្តរក្រសួងនេះ មានគោលបំណងធានាប្រសិទ្ធភាពកិច្ចសហការរវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (ហៅកាត់ថា អគរ) នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាមួយអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (ហៅកាត់ថា កាំកុងត្រូល) នៃក្រសួងពាណិជ្ជកម្ម ក្នុងការត្រួតពិនិត្យគុណភាព និង/ឬ សុវត្ថិភាពទំនិញនាំចេញ-នាំចូល។

ប្រការ ២.-

ប្រកាសអន្តរក្រសួងនេះ មានគោលដៅកំណត់យន្តការនៃកិច្ចសហការរបស់ អគរ និងកាំកុងត្រូល ពាក់ព័ន្ធនឹងការត្រួតពិនិត្យគុណភាព និង/ឬ សុវត្ថិភាពទំនិញ ការវិភាគសំណាកគំរូ និងការផ្លាស់ប្តូរព័ត៌មាន។

ប្រការ ៣.-

ប្រកាសអន្តរក្រសួងនេះ មានវិសាលភាពអនុវត្តចំពោះតែករណី អគរ ស្នើសុំកិច្ចសហការក្នុងការត្រួតពិនិត្យគុណភាព និង/ឬ សុវត្ថិភាពទំនិញនាំចេញ-នាំចូល ស្របតាមគោលការណ៍គ្រប់គ្រងហានិភ័យ។

ប្រការ ៤.-

កំណត់យន្តការនៃកិច្ចសហការរបស់ អគរ ពាក់ព័ន្ធនឹងការត្រួតពិនិត្យគុណភាព និង/ឬ សុវត្ថិភាពទំនិញ ការវិភាគសំណាកគំរូ និងការផ្លាស់ប្តូរព័ត៌មាន ស្របតាមគោលនយោបាយសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ដូចតទៅ÷

១- អគរ ជាស្ថាប័នតែមួយគត់មានសមត្ថកិច្ចក្នុងការត្រួតពិនិត្យទំនិញនាំចេញ-នាំចូល។ ក្នុងករណីតម្រូវឱ្យមានអ្នកឯកទេសជាក់លាក់ អគរ អាចស្នើសុំអ្នកឯកទេសតាមចំនួនសមស្របពីកាំកុងត្រូល តាមទម្រង់ក្នុងឧបសម្ព័ន្ធទី (១) នៃប្រកាសនេះ ក្នុងការត្រួតពិនិត្យគុណភាព និង/ឬ សុវត្ថិភាពទំនិញ តាមពេលវេលានិងទីតាំងដែលកំណត់និងសម្របសម្រួលដោយ អគរ។ អគរ និងកាំកុងត្រូល ត្រូវធ្វើរបាយការណ៍រួមគ្នា ចំពោះមុខទំនិញដែលជាកម្មវត្ថុត្រូវដកយកសំណាកគំរូ ដើម្បីត្រួតពិនិត្យគុណភាព និង/ឬ សុវត្ថិភាព តាមទម្រង់ក្នុងឧបសម្ព័ន្ធទី (២) នៃប្រកាសនេះ។

២- ក្នុងករណីកាំកុងត្រូលខកខានមិនបានឆ្លើយតបនឹងសំណើក្នុងចំណុចទី១ នៃប្រការនេះ ក្នុងរយៈពេល ៨ (ប្រាំបី) ម៉ោង នៃម៉ោងធ្វើការ ទំនិញដែលជាកម្មវត្ថុនៃការស្នើសុំត្រួតពិនិត្យនោះ ត្រូវបានចាត់ទុកថាពុំមានហានិភ័យ។

៣- អគរ អាចផ្ញើសំណាកគំរូទំនិញដែលបានដកសម្រាប់ធ្វើការវិភាគស្របតាមវិធីសាស្ត្រយកគំរូ បញ្ជូនទៅកាំកុងត្រូល អមភ្ជាប់ដោយលិខិតតាមទម្រង់ក្នុងឧបសម្ព័ន្ធទី (៣) នៃប្រកាសនេះ។

៤- តាមរយៈព័ត៌មានហានិភ័យលើមុខទំនិញឬមុខសញ្ញាធុរជនណាមួយ ដែលផ្តល់ដោយកាំកុងត្រូល អគរ ត្រូវពិនិត្យលទ្ធភាពនៃការចាត់វិធានការតាមស្ថានភាពជាក់ស្តែង ដោយឈរលើគោលការណ៍នៃការរក្សាបាននូវតុល្យភាពនៃកិច្ចសម្រួលពាណិជ្ជកម្មនិងការធានាអនុលោមភាព។ ប្រសិនបើវិធានការណាមួយត្រូវបានអនុវត្តដោយផ្អែកលើព័ត៌មានហានិភ័យនេះ អគរ ត្រូវផ្តល់របាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យរូបវន្ត និង/ឬ សូចនាករទំនិញ និង/ឬ ធុរជនពាក់ព័ន្ធនានា ជូនកាំកុងត្រូលតាមទម្រង់ក្នុងឧបសម្ព័ន្ធទី (៤) នៃប្រកាសនេះ។

ប្រការ ៥.-

កំណត់យន្តការនៃកិច្ចសហការរបស់កាំកុងត្រូល ពាក់ព័ន្ធនឹងការត្រួតពិនិត្យគុណភាព និង/ឬ សុវត្ថិភាពទំនិញ ការវិភាគសំណាកគំរូ និងការផ្លាស់ប្តូរព័ត៌មាន ស្របតាមគោលនយោបាយសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ដូចតទៅ÷

១- នៅពេលមានការស្នើសុំជាផ្លូវការពី អគរ នូវអ្នកឯកទេសដើម្បីត្រួតពិនិត្យគុណភាព និង/ឬ សុវត្ថិភាពទំនិញ កាំកុងត្រូលត្រូវសហការត្រួតពិនិត្យក្រោមការសម្របសម្រួលដោយ អគរ។ ក្រោយការត្រួតពិនិត្យ អគរ និងកាំកុងត្រូល ត្រូវធ្វើរបាយការណ៍រួមគ្នា ចំពោះមុខទំនិញដែលជាកម្មវត្ថុត្រូវដកយកសំណាកគំរូ ដើម្បីត្រួតពិនិត្យគុណភាព និង/ឬ សុវត្ថិភាព តាមទម្រង់ក្នុងឧបសម្ព័ន្ធទី (២) នៃប្រកាសនេះ។ កាំកុងត្រូល ត្រូវចេញនូវវិញ្ញាបនបត្រវិភាគលើប៉ារ៉ាម៉ែតដែលបានតម្រូវជាក់លាក់មួយចំនួន ក្នុងរយៈពេលមិនលើសពី ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃត្រួតពិនិត្យ។

២- នៅពេលមានការស្នើសុំដូចចំណុច ១ នៃប្រការនេះ កាំកុងត្រូលត្រូវឆ្លើយតបមក អគរ ឱ្យបានឆាប់មិនលើសពី ៨ (ប្រាំបី) ម៉ោង នៃម៉ោងធ្វើការ គិតចាប់ពីពេលស្នើសុំ ដើម្បីឱ្យការត្រួតពិនិត្យអាចអនុវត្តបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។ ក្នុងករណីមិនអាចបញ្ជូនអ្នកឯកទេសក្នុងការត្រួតពិនិត្យតាមការស្នើសុំបាន កាំកុងត្រូលត្រូវបញ្ជាក់ពីមូលហេតុជាលាយលក្ខណ៍អក្សរ ដើម្បី អគរ អាចចាត់វិធានការផ្សេងទៀត តាមភាពចាំបាច់។

៣- ចំពោះការស្នើសុំធ្វើការវិភាគសំណាកគំរូទំនិញ កាំកុងត្រូលត្រូវឆ្លើយតប និងណែនាំពីវិធីសាស្ត្រយកគំរូមក អគរ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ កាំកុងត្រូលត្រូវផ្តល់លទ្ធផលវិភាគជូន អគរ ក្នុងរយៈពេលមិនលើសពី ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីទទួលបានសំណាកគំរូ។ ក្នុងករណីមិនអាចធ្វើការវិភាគ ឬមិនអាចធ្វើទាន់តាមពេលវេលាកំណត់នេះ កាំកុងត្រូលត្រូវធ្វើការបញ្ជាក់ពីមូលហេតុជាលាយលក្ខណ៍អក្សរ។

៤- ក្នុងករណីសង្ស័យថាមានហានិភ័យលើមុខទំនិញ ឬមុខសញ្ញាធុរជនណាមួយ ដែលជាលទ្ធផលនៃការរកឃើញក្នុងដែនសមត្ថកិច្ចរបស់ខ្លួន កាំកុងត្រូលត្រូវបញ្ជូនព័ត៌មានហានិភ័យនេះមក អគរ ដើម្បីចាត់វិធានការទាន់ពេល តាមទម្រង់ក្នុងឧបសម្ព័ន្ធទី (៥) នៃប្រកាសនេះ។

ប្រការ ៦._

យន្តការកិច្ចសហការរវាង អគរ និងកាំកុងត្រូល ត្រូវដំណើរការកិច្ចប្រជុំទាំងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋានតាមការចាំបាច់ ឬតាមការអញ្ជើញរបស់អគ្គនាយកដ្ឋានណាមួយ ដើម្បីផ្សព្វផ្សាយបទប្បញ្ញត្តិពាក់ព័ន្ធ និងពិនិត្យវឌ្ឍនភាពនៃការគ្រប់គ្រងនិងត្រួតពិនិត្យទំនិញនាំចេញ-នាំចូល ស្របតាមគោលនយោបាយសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ។

អគរ និងកាំកុងត្រូល ត្រូវរៀបចំនិងធ្វើបច្ចុប្បន្នភាពឱ្យគ្នាទៅវិញទៅមកនិងទាន់ពេលវេលានូវបញ្ជីឈ្មោះមន្ត្រី និងទីកន្លែងទំនាក់ទំនងព័ត៌មានថ្នាក់នាយកដ្ឋាន សាខា និងការិយាល័យពាក់ព័ន្ធ តាមទម្រង់ក្នុងឧបសម្ព័ន្ធ (៦) នៃប្រកាសនេះ។

អគ្គនាយកដ្ឋានទាំងពីរត្រូវជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីឱ្យការផ្លាស់ប្តូរព័ត៌មាន និងការស្នើសុំកិច្ចសហការ អាចធ្វើឡើងតាមមធ្យោបាយអេឡិចត្រូនិច។ ក្នុងករណីបន្ទាន់ ការទាក់ទងសុំកិច្ចសហការអាចធ្វើឡើងដោយផ្ទាល់មាត់ តាមរយៈទូរស័ព្ទ ឬតាមតេឡេក្រាម។

ប្រការ ៧._

អគ្គនាយកដ្ឋានទាំងពីរមានកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈ តាមបទប្បញ្ញត្តិជាធរមាន ដោយមិនត្រូវបញ្ចេញ ឬធ្វើឱ្យបែកចេញនូវព័ត៌មាន និង/ឬ ទិន្នន័យនានា ដែលជាកម្មវត្ថុនៃការផ្លាស់ប្តូរទៅវិញទៅមក ក្នុងក្របខណ្ឌនៃកិច្ចសហការតាមបញ្ញត្តិប្រកាសនេះទៅតតិយជន ដោយពុំមានការអនុញ្ញាតពីថ្នាក់ដឹកនាំឡើយ។

ប្រការ ៨.-

ប្រកាសអន្តរក្រសួងលេខ ៩៩៤ សហវ.ប្រក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៩.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១២ កើត ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០១៩

ឧបនាយករដ្ឋមន្ត្រី	**រដ្ឋមន្ត្រី**
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	**ក្រសួងពាណិជ្ជកម្ម**
អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន	**ប៉ាន សូរស័ក្តិ**

កន្លែងទទួល ÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ឧបសម្ព័ន្ធទី (១) ទម្រង់លិខិតស្នើសុំអ្នកឯកទេសត្រួតពិនិត្យគុណភាព និង/ឬ សុវត្ថិភាពទំនិញ
នៃប្រកាសអន្តរក្រសួងលេខ[illegible] ចុះថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៩ ស្តីពីកិច្ចសហការរវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

នាយកដ្ឋាន/សាខា/ការិយាល័យ.........

លិខិតស្នើសុំអ្នកឯកទេស

ត្រួតពិនិត្យគុណភាព និង/ឬ សុវត្ថិភាពទំនិញ

លេខ÷...........................

ស្នើសុំអញ្ជើញ ÷ អ្នកឯកទេសចំនួន...........នាក់ នៃនាយកដ្ឋាន/សាខា/ការិយាល័យ.................................

ដើម្បីចូលរួម ÷ ត្រួតពិនិត្យគុណភាព និង/ឬ សុវត្ថិភាពទំនិញរបស់ក្រុមហ៊ុន..

កាលបរិច្ឆេទ ÷ ថ្ងៃ...................ទី............ខែ...............ឆ្នាំ២០១៩ វេលាម៉ោង.................................

ទីកន្លែង ÷ ....

មូលហេតុ ÷ ....

....

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

....................ថ្ងៃទី ខែ ឆ្នាំ២០១៩

ប្រធាននាយកដ្ឋាន/សាខា/ការិយាល័យ..........

បញ្ជាក់÷

ករណីខគខានមិនបានឆ្លើយតបក្នុងរយៈពេល៨ម៉ោង នៃម៉ោងធ្វើការ ទំនិញដែលជាកម្មវត្ថុនៃការស្នើសុំត្រួតពិនិត្យនោះ ត្រូវបានចាត់ទុកថាពុំមានហានិភ័យ។

ឧបសម្ព័ន្ធទី (២) ទម្រង់របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាព និង/ឬ សុវត្ថិភាពទំនិញ
នៃប្រកាសអន្តរក្រសួងលេខ[illegible] ចុះថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៩ ស្តីពីកិច្ចសហការរវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ៍ណ៍ អាហរ៍ណ៍ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា	កាំកុងត្រូល
នាយកដ្ឋាន/សាខា/ការិយាល័យ.........	នាយកដ្ឋាន/សាខា/ការិយាល័យ.........

របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាព និង/ឬ សុវត្ថិភាពទំនិញ

លេខ÷...........................

I- យោង

1. លិខិតស្នើសុំអ្នកឯកទេសលេខ ÷ .... ចុះថ្ងៃទី.......... ខែ.............. ឆ្នាំ២០១៩
2. ប្រតិវេទន៍គយលេខ ÷ .... ចុះថ្ងៃទី.......... ខែ.............. ឆ្នាំ២០១៩

II- សមាសភាព

1. មន្ត្រីគយនិងរដ្ឋាករ
   - ឈ្មោះ.. អត្តលេខ...........................
   - ឈ្មោះ.. អត្តលេខ...........................
2. អ្នកឯកទេសកាំកុងត្រូល
   - ឈ្មោះ.. អត្តលេខ...........................
   - ឈ្មោះ.. អត្តលេខ...........................
3. ម្ចាស់ទំនិញ ឬតំណាងម្ចាស់ទំនិញ
   - ឈ្មោះ...................................... អត្តសញ្ញាណប័ណ្ណលេខ......................

III- ការត្រួតពិនិត្យគុណភាព និង/ឬ សុវត្ថិភាពទំនិញ

1. ប្រព្រឹត្តកម្មហានិភ័យដោយប្រព័ន្ធ ASYCUDA
   ☐ ច្រកពណ៌បៃតង ☐ ច្រកពណ៌ខៀវ ☐ ច្រកពណ៌លឿង ☐ ច្រកពណ៌ក្រហម
2. ការប្រកាសរបស់ម្ចាស់ ឬតំណាងម្ចាស់ទំនិញ
   - ឈ្មោះទំនិញ ÷ ....
   - លេខកូដទំនិញ ÷ ....
3. លទ្ធផលនៃការត្រួតពិនិត្យ
   - ក្រោយធ្វើការវិភាគសំណាកគំរូទំនិញ អ្នកឯកទេសកាំកុងត្រូលបានបញ្ជាក់លទ្ធផលដូចខាងក្រោម៖
   ☐ មាន ☐ គ្មាន គុណភាពសម្រាប់ការប្រើប្រាស់

☐ មាន ☐ គ្មាន សុវត្ថិភាពសម្រាប់ការប្រើប្រាស់

☐ ត្រូវវិភាគសំណាកគំរូជាមុន

☐ ផ្សេងទៀត..

- កាំកុងត្រូលត្រូវចេញវិញ្ញាបនបត្រវិភាគលើប៉ារ៉ាម៉ែតដែលបានតម្រូវជាក់លាក់មួយចំនួន ក្នុងរយៈពេលមិនលើសពី ១៥ថ្ងៃ គិតចាប់ពីថ្ងៃត្រួតពិនិត្យនេះ។

IV- **ការសន្និដ្ឋាន**

1. ☐ អនុញ្ញាតឱ្យធ្វើការនាំចូល/ នាំចេញ
2. ☐ ផ្អាកជាបណ្ដោះអាសន្នមិនឱ្យនាំចូល/ នាំចេញ
3. ☐ ផ្សេងទៀត ....

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

....................ថ្ងៃទី ខែ ឆ្នាំ២០១៩

ប្រធាននាយកដ្ឋាន/សាខា/ការិយាល័យ......... **ប្រធាននាយកដ្ឋាន/សាខា/ការិយាល័យ.........**

(អគរ) *(កាំកុងត្រូល)*

ឧបសម្ព័ន្ធទី (៣) ទម្រង់លិខិតស្នើសុំធ្វើការវិភាគសំណាកគំរូទំនិញ

នៃប្រកាសអន្តរក្រសួងលេខ[illegible] ចុះថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៩ ស្តីពីកិច្ចសហការរវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

នាយកដ្ឋាន/សាខា/ការិយាល័យ.........

លិខិតស្នើសុំធ្វើការវិភាគសំណាកគំរូទំនិញ

លេខ÷...........................

I- **យោង**

1. ប្រតិវេទន៍គយលេខ ÷ .... ចុះថ្ងៃទី........... ខែ.............. ឆ្នាំ២០១៩

II- **អំពីសំណាកគំរូទំនិញ**

1. **សំណាកគំរូទំនិញទី ១**
   - ឈ្មោះទំនិញ ÷ ....
   - លេខសម្គាល់សំណាកគំរូ ÷ ....
   - បរិមាណសំណាកគំរូ ÷ .... ទម្ងន់÷..............................
2. **សំណាកគំរូទំនិញទី ២, ៣, ...**
   - ឈ្មោះទំនិញ ÷ ....
   - លេខសម្គាល់សំណាកគំរូ ÷ ....
   - បរិមាណសំណាកគំរូ ÷ .... ទម្ងន់÷..............................

III- **តម្រូវការលទ្ធផលនៃការធ្វើវិភាគ**

1. ☐ ការបញ្ជាក់អំពីគុណភាពទំនិញសម្រាប់ការប្រើប្រាស់
2. ☐ ការបញ្ជាក់អំពីសុវត្ថិភាពទំនិញសម្រាប់ការប្រើប្រាស់
3. ☐ ផ្សេងទៀត..

IV- **មូលហេតុនៃការស្នើសុំធ្វើការវិភាគ**

1. ☐ ការសង្ស័យលើគុណភាព និង/ឬ សុវត្ថិភាពទំនិញដោយមន្ត្រីគយនិងរដ្ឋាករ
2. ☐ ព័ត៌មានហានិភ័យដែលផ្តល់ដោយកាំកុងត្រូល
3. ☐ ផ្សេងទៀត..

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

...................ថ្ងៃទី ខែ ឆ្នាំ២០១៩

ប្រធាននាយកដ្ឋាន/សាខា/ការិយាល័យ

ឧបសម្ព័ន្ធទី (៤) ទម្រង់របាយការណ៍ស្តីពីការត្រួតពិនិត្យទំនិញ

នៃប្រកាសអន្តរក្រសួងលេខ[illegible] ចុះថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៩ ស្តីពីកិច្ចសហការរវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ៍ណ អាហារណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

នាយកដ្ឋាន/សាខា/ការិយាល័យ.........

របាយការណ៍ស្តីពីការត្រួតពិនិត្យទំនិញ

លេខ÷..........................

I- យោង

1. លិខិតផ្តល់ព័ត៌មានហានិភ័យលេខ ÷ .... ចុះថ្ងៃទី.......... ខែ.............. ឆ្នាំ២០១៩
2. ប្រតិវេទន៍គយលេខ ÷ .... ចុះថ្ងៃទី.......... ខែ.............. ឆ្នាំ២០១៩

II- សមាសភាព

1. មន្ត្រីគយនិងរដ្ឋាករ
   - ឈ្មោះ... អត្តលេខ..........................
   - ឈ្មោះ... អត្តលេខ..........................
2. ម្ចាស់ទំនិញ ឬតំណាងម្ចាស់ទំនិញ
   - ឈ្មោះ...................................... អត្តសញ្ញាណប័ណ្ណលេខ.....................

III- ការត្រួតពិនិត្យទំនិញ

1. ប្រព្រឹត្តកម្មហានិភ័យដោយប្រព័ន្ធ ASYCUDA World

   ☐ ច្រកពណ៌បៃតង ☐ ច្រកពណ៌ខៀវ ☐ ច្រកពណ៌លឿង ☐ ច្រកពណ៌ក្រហម

2. ការប្រកាសរបស់ម្ចាស់ ឬតំណាងម្ចាស់ទំនិញ
   - ឈ្មោះទំនិញ ÷ ....
   - លេខកូដទំនិញ ÷ ....
   - ក្រុមហ៊ុននាំចូល ÷ ....
3. លទ្ធផលនៃការត្រួតពិនិត្យ

   ផ្អែកលើប្រព័ន្ធគ្រប់គ្រងហានិភ័យគយ បានធ្វើការត្រួតពិនិត្យទំនិញ........% ដោយផ្ទៀងផ្ទាត់ជាមួយឯកសារ និងបានទទួលលទ្ធផលដូចខាងក្រោម÷

   ☐ សមស្របតាមការប្រកាស និងគ្មានហានិភ័យ ☐ សមស្របតាមការប្រកាស ប៉ុន្តែមានហានិភ័យ

   ☐ មិនសមស្របតាមការប្រកាស ប៉ុន្តែគ្មានហានិភ័យ ☐ មិនសមស្របតាមការប្រកាស និងមានហានិភ័យ

IV- **ការដោះស្រាយហានិភ័យ**

1. ☐ ហាមឃាត់ការនាំចូល/នាំចេញជាបណ្តោះអាសន្ន
2. ☐ ដកសំណាកគំរូទំនិញបញ្ជូនទៅកាំកុងត្រូល ដើម្បីធ្វើការវិភាគ
3. ☐ ប្រមូលសូចនាករបន្ថែមពាក់ព័ន្ធនឹងទំនិញបញ្ជូនទៅកាំកុងត្រូល

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

....................ថ្ងៃទី ខែ ឆ្នាំ២០១៩

ប្រធាននាយកដ្ឋាន/សាខា/ការិយាល័យ..........

ឧបសម្ព័ន្ធទី (៥) ទម្រង់លិខិតផ្តល់ព័ត៌មានហានិភ័យ

នៃប្រកាសអន្តរក្រសួងលេខ[illegible] ចុះថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៩ ស្តីពីកិច្ចសហការរវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

កាំកុងត្រូល

នាយកដ្ឋាន/សាខា/ការិយាល័យ.........

លិខិតផ្តល់ព័ត៌មានហានិភ័យ

លេខ÷...........................

I- ការកំណត់ហានិភ័យ

1. ឈ្មោះទំនិញ ÷ ....
2. លេខកូដទំនិញ (បើមាន) ÷ ....
3. ម៉ាកយីហោទំនិញ ÷ ....
4. ប្រទេសដើមកំណើត ÷ ....
5. ឈ្មោះក្រុមហ៊ុននាំចូល (បើមាន) ÷ ....
6. ព័ត៌មានផ្សេងទៀត ÷ ....

II- ការវិភាគ និងការវាយតម្លៃហានិភ័យ

1. បរិយាយផលវិបាក ÷ ....
2. ទំហំផលវិបាក ÷ ....
3. កម្រិតហានិភ័យ ÷ ☐ ខ្ពស់ ☐ មធ្យម

III- ការដោះស្រាយហានិភ័យ

កម្រិតហានិភ័យ	វិធានត្រូវអនុវត្ត
1. ☐ ខ្ពស់	ផ្អាកជាបណ្តោះអាសន្នមិនឱ្យនាំចូល/ នាំចេញ
2. ☐ មធ្យម	ត្រូវការធ្វើវិភាគសំណាកគំរូទំនិញ

IV- កំណត់សម្គាល់ ឬវិធានផ្សេងទៀត

....

....

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

...................ថ្ងៃទី ខែ ឆ្នាំ២០១៩

ប្រធាននាយកដ្ឋាន/សាខា/ការិយាល័យ.........

ឧបសម្ព័ន្ធទី (៦) ទម្រង់បញ្ជីកំណត់ទីកន្លែងទំនាក់ទំនងព័ត៌មាន

នៃប្រកាសអន្តរក្រសួងលេខ[illegible] ចុះថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៩ ស្តីពីកិច្ចសហការរវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ្ឌ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋាន.....................

លេខ÷...........................

បញ្ជីកំណត់ទីកន្លែងទំនាក់ទំនងព័ត៌មាន

ល.រ	អង្គភាព	ឈ្មោះមន្ត្រី	ឋានៈ	លេខទូរស័ព្ទ	អ៊ីមែល

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

...................ថ្ងៃទី ខែ ឆ្នាំ២០១៩

ប្រតិភូរាជរដ្ឋាភិបាល

ទទួលបន្ទុកជាអគ្គនាយក.....................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០១៣.[illegible]

ថ្ងៃ[illegible]ខែ[illegible]ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី....១៣.....ខែ មករា..ឆ្នាំ២០១៩

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/ ០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងប្តូរប្រកាសបង្កើតរោងចក្រថ្មី ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ក្រុមហ៊ុន ដេលី ណែឈរល ហ្វូតស្តាហ្វ

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន ដេលី ណែឈរល ហ្វូតស្តាហ្វ (DAILY NATURAL FOODSTUFF CO., LTD.) តំណាងដោយ លោក ស៊ីង ចេងឃាង បង្កើតរោងចក្រផលិតទឹកត្រី ដែលមានទីតាំងស្ថិតនៅដីឡូតិ៍លេខ៦៤៤ ផ្លូវ៣៦៩ ភូមិអូរអណ្តូង សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ / ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax: 855-23-428263

ឈ្មោះផលិតផល	**លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code**
ទឹកត្រី	១០៧៩

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្ដីណែនាំស្ដីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ផ្លាកឈ្មោះរោងចក្រ៖ " រោងចក្រផលិតទឹកត្រី ដេលី ណែឈរលេ ហ្វ៊ូតស្ដាហ្វ "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្ដូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្ដូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្ដូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្ដាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាន់ហេតុការណ៍អំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ ប្រកាសបង្កើតរោងចក្រលេខ៦៧១ ឧស.ក២.ប្រក.១១ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

រដ្ឋលេខាធិការ

មាន សុភា

ចម្លងជូន៖

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-អគ្គនាយកដ្ឋានរាជកិច្ច និងតម្កល់ឯកសារជាតិ
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលារាជធានីភ្នំពេញ
-មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ
-រដ្ឋបាលខណ្ឌច្បារអំពៅ
-រដ្ឋបាលសង្កាត់ព្រែកប្រា
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០៨៤ [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ [illegible] ឆ្នាំ២០១៩

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/ ០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ០០០៧/១៨ ស.ត.ស.ព ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញសំណើសុំប្រកាសបង្កើតរោងចក្រផលិតស៊ីម៉ងត៍ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ របស់ក្រុមហ៊ុន យីង អេលីហ្វិន ខនស្ត្រាក់សិន មេធៀរៀល អ៊ិនដាសស្ទៀល ឯ.ក

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន យីង អេលីហ្វិន ខនស្ត្រាក់សិន មេធៀរៀល អ៊ិនដាសស្ទៀល ឯ.ក (KING ELEPHANT CONSTRUCTION MATERIAL INDUSTRIAL CO., LTD.) តំណាងដោយ លោក **SHENG, QIAOHONG** បង្កើតរោងចក្រផលិតស៊ីម៉ងត៍ ដែលមានទីតាំងស្ថិតនៅ តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (ភូមិពូធឿង ឃុំបិតត្រាំង និងភូមិស្មាច់ដែង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ)។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax: 855-23-428263

ឈ្មោះផលិតផល	**លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code
ស៊ីម៉ងត៍	២៣៩៤

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ផ្លាកឈ្មោះរោងចក្រ៖ " រោងចក្រផលិតស៊ីម៉ងត៍ យីង អេលីហ្វិន ខនស្រ្តាក់សិន មេធៀរៀល អ៊ិនដាសស្ទ្រៀល ឯ.ក "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្ដល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្ដន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៥៖ ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

រដ្ឋលេខាធិការ

មាន សុភា

ចម្លងជូន៖
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គនាយកដ្ឋានរាជកិច្ច និងតម្កល់ឯកសារជាតិ
- វិទ្យាស្ថានស្តង់ដារកម្ពុជា
- មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- សាលាខេត្តព្រះសីហនុ
- មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះសីហនុ
- អង្គភាពរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ
- រដ្ឋបាលស្រុកព្រៃនប់
- រដ្ឋបាលឃុំបិតត្រាំង និងឃុំរាម

  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០១៥ ឧ.ស.ក.ព.ក.០១

ថ្ងៃ...សុក្រ ៦កើត... ខែ...បុស្ស... ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១១... ខែ...មករា... ឆ្នាំ២០១៩

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/ ០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៩៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ៧៧៩/១៨ ក.ត.ស.ព ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញសំណើសុំប្រកាសបង្កើតរោងចក្រផលិតបន្ទះសូឡា និងគ្រឿងបង្គុំ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ របស់ក្រុមហ៊ុន អេណាឡិច អេនើជី (ខេអេច) ឯ.ក

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន អេណាឡិច អេនើជី (ខេអេច) ឯ.ក (ENALEX ENERGY (KH) CO., LTD.) តំណាងដោយ លោក **LI, KEMIN** បង្កើតរោងចក្រផលិតបន្ទះសូឡា និងគ្រឿងបង្គុំ ដែលមានទីតាំងស្ថិតនៅ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (សង្កាត់ភ្លើងឆេះរទេះ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ)។

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
បន្ទះសូឡា និងគ្រឿងបង្គុំ	២៣១០

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ផ្លាកឈ្មោះរោងចក្រ៖ " រោងចក្រផលិតបន្ទះសូឡា និងគ្រឿងបង្គុំ អេណាឡិច អេនើជី (ខេអេច) ឯ.ក "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៨នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាន់ហេតុការណ៍អំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៥៖ ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

រដ្ឋលេខាធិការ

ម៉ាន សុភា

ចម្លងជូន៖

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-អគ្គនាយកដ្ឋានរាជកិច្ច និងតម្កល់ឯកសារជាតិ
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលារាជធានីភ្នំពេញ
-មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ
-អង្គភាពរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ
-រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ
-រដ្ឋបាលសង្កាត់ភ្លើងឆេះរទេះ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី